00224205

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ឯកសារ/Doc: D97/III

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 09 / 2008
ម៉ោង (Time/Heure): 16:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម

# Order on Application at the ECCC of the Form of Responsibility Known as Joint Criminal Enterprise

# Ordonnance sur l'application de la forme de responsabilité connue sous le nom d'Entreprise criminelle commune

យើង យូ ប៊ុនឡេង និង ម៉ាសែល ឡឺម៉ុង (Marcel LEMONDE) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ៥៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ ឈ្មោះ**អៀង សារី និង អ្នកដទៃ**
ត្រូវបានដាក់ឲ្យនៅក្រោមការពិនិត្យចំពោះឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាម មាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

00224206

ឯកសារ: D97/III

បានឃើញពាក្យសុំ (D97) របស់ក្រុមមេធាវីការពារក្តី **អៀង សារី** ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ ដែលស្នើសុំថា សញ្ញាណនៃសហឧក្រិដ្ឋកម្មរួម មិនត្រូវចាត់ទុកជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញទេ

បានឃើញពាក្យសុំ (D97/I) ក្រោយមកទៀតរបស់ក្រុមមេធាវីដដែលចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៨ ដែលស្នើសុំ *"ដោយអនុវត្តន៍មាត្រា ៨.៤ នៃសេចក្តីណែនាំអំពីការដាក់ឯកសារនៅ អ.វ.ត.ក នូវសវនាការមួយ ឬក៏ការពន្យារពេលសម្រាប់មេធាវីការពារក្តី ដើម្បីធ្វើការឆ្លើយតបចំពោះចម្លើយជាយថាហេតុរបស់សហព្រះរាជអាជ្ញា"*

បានឃើញសារណារបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៨ (D97/II)

យល់ឃើញថា មាត្រា ៨ នៃសេចក្តីណែនាំអំពីការដាក់ឯកសារនៅ អ.វ.ត.ក អនុវត្តតែចំពោះអង្គជំនុំជម្រះប៉ុណ្ណោះ គឺមិនអនុវត្តចំពោះសហចៅក្រមស៊ើបអង្កេតទេ ដូច្នេះ ពាក្យសុំចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៨ ត្រូវចាត់ទុកថាមិនត្រឹមត្រូវ

យល់ឃើញថា ការអនុវត្តន៍ជាយថាហេតុនៃសញ្ញាណសហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿងនេះពិតជាមានសារៈសំខាន់។ យល់ឃើញថា ស្របតាមវិធាន ៦៧-២ នៃវិធានផ្ទៃក្នុងសហចៅក្រមស៊ើបអង្កេត ដោយផ្អែកតាមភស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ត្រូវសម្រេចនៅក្នុងដីកាដំណោះស្រាយ ពីលក្ខណៈ និងទម្រង់នៃការទទួលខុសត្រូវរបស់អ្នកដែលត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះ

ដោយផ្អែកលើចំណុចនេះ យល់ឃើញថា ពាក្យសុំរបស់ក្រុមមេធាវីការពារក្តី **អៀង សារី** ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ ព្រមទាំងសារណារបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៨ បង្កើតបានជាការរួមចំណែកសំខាន់ដល់ការពិចារណារបស់សហចៅក្រមស៊ើបអង្កេត

ប៉ុន្តែ យល់ឃើញថា បញ្ហាដែលលើកឡើងនេះ មិនពាក់ព័ន្ធតែក្រុមមេធាវីការពារក្តី **អៀង សារី** ប៉ុណ្ណោះទេ តែវាក៏ពាក់ព័ន្ធនឹងជនត្រូវចោទដទៃទៀត រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ដូច្នេះវាជា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00224207

ឯកសារ: D97/III

ការចាំបាច់ក្នុងការស្នើឲ្យគ្រប់ភាគីទាំងអស់ធ្វើការកត់សំគាល់របស់ខ្លួន ដើម្បីជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់សហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើសេចក្តីសម្រេច

## ហេតុដូច្នេះ

សម្រេចថា ពាក្យសុំចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៨ មិនត្រឹមត្រូវ

កត់សំគាល់ទុកនូវសេចក្តីសំអាងដែលមាននៅក្នុងពាក្យសុំ **អៀង សារី** ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ និង ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៨

ស្នើឲ្យភាគីនានាធ្វើការកត់សំគាល់របស់ខ្លួនបន្ថែមទាក់ទិននឹងបញ្ហានេះឲ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.